ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ២៨៥ សជណ ធទឧ

**សេចក្តីជូនដំណឹងបន្ថែម**

**ស្តីពី ស្ថានភាពអាកាសធាតុ នៅព្រះរាជាណាចក្រកម្ពុជា**

បន្ទាប់ពីបានធ្វើការតាមដានលើស្ថានភាពអាកាសធាតុ រួចមក ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងបន្ថែមដល់សាធារណជនមេត្តាជ្រាបថា : នៅថ្ងៃទី 11 ខែកញ្ញា ឆ្នាំ 2015 នេះ នៅក្នុងសមុទ្រចិនខាងត្បូង មានកើតឡើងនូវសម្ពាធទាបសកម្មមួយ (Active Low Pressure ) ។

យោងតាមការព្យាករ សម្ពាធទាបសកម្មនេះ នឹងវិវត្តទៅជាវិសម្ពាធ (Tropical Depression) នៅថ្ងៃទី 12 ខែកញ្ញា ឆ្នាំ 2015 ហើយនៅថ្ងៃទី 13 ខែកញ្ញា ឆ្នាំ 2015 វានឹងបន្តវិវត្តទៅជាព្យុះ រួចធ្វើដំណើរឆ្ពោះទៅតំបន់ឆ្នេរភាគកណ្តាល នៃប្រទេសវៀតណាម ។

ឥទ្ធិពលនៃព្យុះនេះ នឹងបង្កឱ្យផ្ទៃមេឃនៅព្រះរាជាណាចក្រកម្ពុជាមានពពកច្រើនដេរដាស មានភ្លៀងបន្តធ្លាក់ច្រើនក្នុងក្របខ័ណ្ឌទូទាំងប្រទេស ពិសេស ចាប់ពីថ្ងៃទី 15 ដល់ថ្ងៃទី 18 ខែកញ្ញា ឆ្នាំ 2015 និងអាចបណ្តាលឱ្យរាជធានី-ខេត្ត មួយចំនួនដូចជា : រាជធានី ភ្នំពេញ ខេត្តកំពង់ស្ពឺ កណ្តាល តាកែវ កំពត ព្រះសីហនុ កំពង់ធំ និងខេត្តសៀមរាប ប្រឈមនឹងជំនន់ទឹកភ្លៀង ។

ផ្ទៃមេឃនៅតំបន់មាត់សមុទ្រ និងលើផ្ទៃសមុទ្រ មានសភាពអាប់អួរ ព្រមទាំងមានភ្លៀង និងខ្យល់បក់បោកខ្លាំង ។ រលកសមុទ្រអាចមានកំពស់ពី 1,00 - 2,50 ម៉ែត្រ ។

យោងលើស្ថានភាពអាកាសធាតុ ដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន ពិសេសចំពោះបងប្អូនប្រជានេសាទសមុទ្រ និងអ្នកធ្វើដំណើរទេសចរតាមសមុទ្រ **សូមផ្អាកសកម្មភាព ចាប់ពីថ្ងៃទី 14 ដល់ថ្ងៃទី 18 ខែកញ្ញា ឆ្នាំ 2015 ។**

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៥

**រដ្ឋមន្ត្រី**

**លឹម គានហោ**

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥

# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh